លេខ/No: D11/2/5/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Laurent KASPER-ANSERMET

កាលបរិច្ឆេទ ៖ ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

ភាសា ៖ បារាំង

ចំណាត់ថ្នាក់ឯកសារ ៖ សាធារណៈ

---

# ដីកាសម្រេចស្ដីពីការពិចារណាឡើងវិញលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល (Robert Hamill)

---

<u>សហព្រះរាជអាជ្ញា</u>
លោកស្រី ជា លាង
លោក Andrew CAYLEY

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
23 / 03 / 2012
ម៉ោង (Time/Heure) : 9:30am
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Rupert Chesnay

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស. លេខ/No: D11/2/5/1

យើង **Laurent Kasper-Ansermet** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“*អ.វ.ត.ក.*”)

**បានឃើញ**កិច្ចព្រមព្រៀងចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (“កិច្ចព្រមព្រៀងស្ដីពីការបង្កើត *អ.វ.ត.ក*”)។

**បានឃើញ**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧ (“ក្រមនីតិវិធីព្រហ្មទណ្ឌ”)។

**បានឃើញ**ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (“ច្បាប់ស្ដីពីការបង្កើត *អ.វ.ត.ក*”)។

**បានឃើញ**ការស៊ើបសួរដែលកំពុងបន្តដំណើរការ ប្រឆាំងនឹងជនសង្ស័យ ទាក់ទិននឹងបទចោទ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាត** ជាបទល្មើសដែលមានចែងនិងផ្ដន្ទាទោស តាមមាត្រា ៣, ៤, ៥, ៦, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

**បានឃើញ**វិធាន ១២ វិធាន ១២ *ស្ទួន* វិធាន ២១ វិធាន ២៣ វិធាន ២៣ *ស្ទួន* វិធាន ២៣ *ស្ទួនពីរ* វិធាន ៤៩ វិធាន៥៣ វិធាន ៥៥ វិធាន ៥៦(២)(ក) វិធាន ៦៦ និង វិធាន ១០០ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

**បានឃើញ**មាត្រា ១ មាត្រា ៣ និងមាត្រា ៦ នៃសេចក្ដីណែនាំអនុវត្ត ២០០៧/០២ ស្ដីពីការចូលរួមរបស់ជនរងគ្រោះ (“សេចក្ដីណែនាំអនុវត្ត”)។

**បានឃើញ**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងកាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[២]។

**បានឃើញ**សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១[៣]។

**បានឃើញ**ដីកាសម្រេចស្តីពីការបើកការស៊ើបសួរឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១[៤] ដែលត្រូវបានចេញ បន្ទាប់ពីមានការពិចារណាឡើងវិញលើសាលដីកាចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ដោយប្រកាសទទួលយកសំណើសុំឲ្យមានកិច្ចស៊ើបសួរ ចំនួនបី ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។

## I. ប្រវត្តិនីតិវិធី

**បានឃើញ**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក **រ៉ូបឺត ហាមីល** ("អ្នកដាក់ពាក្យសុំ") ដែលបានដាក់កាលពីថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១ ជាមួយផ្នែកគាំពារជនរងគ្រោះនៅក្នុងសំណុំរឿង ០០៣ និង ០០៤[៥]។

---

[១] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

[២] ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពី ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[៣] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D13។

[៤] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីពីការបើកការស៊ើបសួរឡើងវិញ ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ D28។

[៥] ផ្នែកគាំពារជនរងគ្រោះ ទម្រង់បែបបទស្តីពីជនរងគ្រោះ លេខ 11-VSS-0002 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១ សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D 11/2។

០០៣/០៧-០៩-២០០៩/អ.វ.ត.ក.--ក.ស.ច.ស.  លេខ/No: D11/2/5/1

**បានឃើញ**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់បន្តជូនសហចៅក្រមស៊ើបអង្កេត ដោយផ្នែកគាំពារជនរងគ្រោះ នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១[៦]។

**បានឃើញ**ការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈដីកាសម្រេចចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ (តទៅនេះហៅថា “ដីកាសម្រេចទីមួយ”)[៧]។

**បានឃើញ**សំណើរបស់អ្នកដាក់ពាក្យសុំចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ស្នើសុំអង្គបុរេជំនុំជម្រះ[៨] ពន្យារពេលកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ ដោយយោងតាមដីកាសម្រេចទីមួយរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីអនុញ្ញាតឲ្យគាត់អាចពិនិត្យមើលសំណុំរឿង ០០៣។

**បានឃើញ**បណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១ ដាក់ជូននៅចំពោះអង្គបុរេជំនុំជម្រះសាលាដំបូង ប្រឆាំងនឹងដីកាសម្រេចទីមួយ[៩] ដោយស្នើសុំជាពិសេសឲ្យគាត់ទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៣។

---

[៦] របាយការណ៍ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ផ្នែកគាំពារជនរងគ្រោះ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១១ សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D11/2/1 សូមមើលអនុស្សរណៈអន្តរការិយាល័យ (សម្ងាត់បំផុត) ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១១។

[៧] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D11/2/3។

[៨] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស សំណើសុំពន្យារពេលកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល រង់ចាំការអនុញ្ញាតឲ្យមានលទ្ធភាពចូលពិនិត្យមើលឯកសារសំណុំរឿង ០០៣ និង០០៤ ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D11/2/4/1។

[៩] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល (ឯកសារ D11/2/3) (សំណុំរឿង ០០៣ និង០០៤) ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D11/2/4/2។

**បានឃើញ**ដីកាសម្រេចដោយមានការកែប្រែជាភាសាអង់គ្លេស របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ជំនួសដីកាសម្រេចទីមួយ ("ដីកាសម្រេចទីពីរ") ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១[១០]។

**បានឃើញ**ការពិចារណារបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១[១១] ដោយផ្តល់សុពលភាពទៅលើដីកាសម្រេចទីមួយ ព្រោះសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបាន [វិធាន ៧៧(១៣)]។

**បានឃើញ**មតិយោបល់ជំទាស់របស់ចៅក្រម Rowan Downing និង Katinka Lahuis នៃអង្គបុរេជំនុំជម្រះ[១២] ដោយប្រកាសថា បណ្តឹងឧទ្ធរណ៍នេះនៅមិនទាន់សម្រេចទេ ព្រោះបណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងប្រឆាំងនឹងដីកាសម្រេចមួយដែលត្រូវបានកែប្រែបន្ទាប់ពី បណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើង។

**បានឃើញ**សំណើចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១[១៣] របស់អ្នកដាក់ពាក្យសុំ ដែលស្នើសុំលទ្ធភាពចូលពិនិត្យមើលសំណុំរឿង ០០៣ និង ០០៤ ព្រមទាំងការពិចារណាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេត លើដីកាសម្រេចទីមួយដែលបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ។

---

[១០] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ D11/2/4/ 4.1។

[១១] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ការពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារ D11/2/4/4។

[១២] ដូចចុងទំព័រខាងលើ លេខ ERN 00748553-00748564។

[១៣] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស សំណើស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការពិចារណាឡើងវិញលើសាលដីកាលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ីត ហាមីល (D11/2/3) (សំណុំរឿង ០០៣ និង០០៤) ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១ ដាក់នៅថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១២។

## II. ភាពអាចទទួលយកបាននៃដីកាសម្រេចបច្ចុប្បន្ន

១. **ដោយហេតុថា** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានស្បថចូលកាន់តំណែងនៅក្នុងកិច្ចប្រជុំពេញអង្គរបស់ចៅក្រម អ.វ.ត.ក កាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ រួចហើយ ហើយបានទទួលតួនាទីប្រកបដោយសុពលភាពពីបុព្វាធិការីដែលបានលាលែងពីតំណែង [មាត្រា ៥(៦) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មាត្រា ១២, ២៣, ២៦ និង ២៧ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក]។

២. ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង **មានអំណាចចេញដីកាសម្រេចនេះ** ដែលភាពអាចទទួលយកដីកាសម្រេចនេះមិនអាចចោទជាមន្ទិលឡើយ ដោយផ្អែកលើមតិយោបល់ថ្មីៗរបស់អង្គបុរេជំនុំជម្រះ[១៤]។

## III. មូលដ្ឋានសម្រាប់ចេញដីកាសម្រេច

### ក.ការពិចារណាឡើងវិញលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៣. **ដោយយល់ឃើញថា** សហចៅក្រមស៊ើបអង្កេត មានអំណាចពិចារណាឡើងវិញលើដីកាសម្រេចមុនៗទាំងអស់ សូម្បីតែក្រោយពេលសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរត្រូវបានចេញផ្សាយហើយក៏ដោយ[១៥]។

---

[១៤] សំណុំរឿង ០០៣/១៦-១២-២០១១/អ.វ.ត.ក/អ.ប.ជ មតិយោបល់របស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចៅក្រម Downing និងចៅក្រម Chung ស្តីពីករណីខ្វែងយោបល់របស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងវិធាន ៧២ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ មតិយោបល់ ១០០២០១២ កថាខណ្ឌ ៤២-៤៧។

[១៥] នៅក្នុងយុត្តិសាស្ត្រតុលាការបារាំង តុលាការព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌ ថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៥ បណ្តឹងសាទុក្ខលេខ 94-84975 ព្រឹត្តិបត្រព្រហ្មទណ្ឌ លេខ ៦ (D 1995 Somm.322 obs. Pradel; JCP 1996 I 3906 chron.J.-H.Robert )។ តុលាការព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៩៨ បណ្តឹងសាទុក្ខលេខ 98-81678 ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២២០។

៤. **ដោយយល់ឃើញថា** ក្នុងករណីដែលវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានចែងពីករណីពិសេសណាមួយ ការណែនាំក្នុងបទដ្ឋាននីតិវិធីអាចត្រូវស្វែងរកក្នុងកម្រិតអន្តរជាតិ[១៦]។

៥. **ដោយយល់ឃើញថា** ច្បាប់អន្តរជាតិចែងថា ដីកាសម្រេចមុនណាមួយអាចត្រូវយកមកពិចារណាឡើងវិញដោយផ្អែកលើមូលដ្ឋានស្របច្បាប់ មិនត្រឹមតែក្នុងករណីមានការប្រែប្រួលកាលៈទេសៈ (អង្គហេតុថ្មី ទឡ្ហីករណ៍ថ្មី) ប៉ុណ្ណោះទេ ប៉ុន្តែក៏ក្នុងករណីដែលដឹងថា ដីកាសម្រេចនោះមានការភ័ន្តច្រឡំ ឬបានបង្កឱ្យមានភាពអយុត្តិធម៌[១៧]

៦. **ដោយយល់ឃើញថា** តុលាការពិសេសសម្រាប់ស៊ីរ៉ាឡេអូន (Special Court for Sierra Leone) បានទទួលស្គាល់ថា ជាគោលការណ៍រួមដើម្បីផលប្រយោជន៍យុត្តិធម៌ តុលាការនីមួយៗអាចធ្វើការកែប្រែ រំលាយចោល ឬពិចារណាឡើងវិញលើដីកាសម្រេចមុនណាមួយ[១៨]។

---

[១៦] មាត្រា ១២(១) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និង មាត្រា ២៣ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[១៧] រឿងក្តី **Milosevic** នៅតុលាការ ICTY [ឆ្នាំ ២០០៥] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំរបស់រដ្ឋអាជ្ញាដើម្បីសុំឱ្យមានការពិចារណាឡើងវិញអំពីភស្តុតាងរបស់សាក្សីផ្នែកការពារក្តីឈ្មោះ Mitar Balevic, Vladislav Jovanovic, Notingkasin Andric និង Dobre Aleksovski និងសេចក្តីសម្រេចតាមការផ្តួចផ្តើមផ្ទាល់ឱ្យមានការពិចារណាឡើងវិញអំពីការទទួលយកវត្ថុតាង ៨៣៧ និង៨៣៨ ពាក់ព័ន្ធនឹងភស្តុតាងរបស់សាក្សីផ្នែកការពារក្តីឈ្មោះ Barry Lituch កថាខណ្ឌ ៧ និងកថាខណ្ឌបន្ទាប់។ ។ រឿងក្តី **Galic** នៅក្នុងតុលាការ ICTY [ឆ្នាំ ២០០១] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើសំណើរបស់អយ្យការសុំឱ្យទទួលយកបណ្តឹងឧទ្ធរណ៍, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ កថាខណ្ឌ១៣ ។ រឿងក្តី **Mucic និងអ្នកផ្សេងទៀត** នៅតុលាការ ICTY [ឆ្នាំ ២០០៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការសម្រេចទោស កថាខណ្ឌ៤៩ ។ រឿងក្តី **Milutinovic និងអ្នកផ្សេងទៀត** នៅតុលាការ ICTY [ឆ្នាំ ២០០៦] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់អយ្យការសុំឱ្យមានការពិចារណាឡើងវិញអំពីសេចក្តីសម្រេចលើសំណើរបស់អយ្យការ សុំឱ្យបន្ថែមវិធានការការពារពាក់ព័ន្ធនឹងសវនការសម្រាប់សាក្សី K56 កថាខណ្ឌ២។ រឿងក្តី **Jadranko Prlic និងអ្នកផ្សេងទៀត** នៅតុលាការ ICTY [ឆ្នាំ ២០០៩] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់ក្រុមមេធាវីការពារក្តីស្នើសុំឱ្យមានការពិចារណាឡើងវិញលើសេចក្តីសម្រេចលើការទទួលយកឯកសារភស្តុតាង កថាខណ្ឌ ២៥។

[១៨] រឿងក្តី **Brima និងអ្នកផ្សេងទៀត** នៅក្នុងតុលាការ SCSL [ឆ្នាំ ២០០៥] មតិយោបល់ស្របគ្នា និងដាច់ដោយឡែករបស់ចៅក្រម Robertson នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី Brima-Kamara ប្រឆាំងនឹងសេចក្តីសម្រេចទទួលសម្លេងភាគច្រើនរបស់អង្គជំនុំជម្រះសាលាដំបូង II លើសំណើរួមគ្នាបន្ទាន់ និងសម្ងាត់ កថាខណ្ឌ ២៤ និង ៤៩។ រឿងក្តី **Norma និងអ្នកផ្សេងទៀត** នៅក្នុងតុលាការ SCSL [ឆ្នាំ ២០០៥] សេចក្តីសម្រេច

៧. **ដោយយល់ឃើញថា** តាមពិត អង្គបុរេជំនុំជម្រះខ្លួនឯង បានធ្វើការពិចារណាឡើងវិញលើដីកាសម្រេចមុនៗ[១៩]។

៨. **ដោយយល់ឃើញថា** ឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការពិចារណាឡើងវិញលើសេចក្តីសម្រេចមុនៗ ត្រូវបានទទួលស្គាល់ដោយច្បាប់ និងយុត្តិសាស្ត្រ[២០]។

៩. **ដោយយល់ឃើញថា** "ភាពមិនប្រក្រតី" ជាច្រើននៅក្នុងកិច្ចដំណើរការនីតិវិធី ដែលបានលើកឡើងនៅក្នុងមតិយោបល់ជំទាស់របស់អង្គបុរេជំនុំជម្រះ ក្នុងចំណោមនោះមានការដាក់ដីកាសម្រេចថ្មីនៅក្នុងសំណុំរឿង កាលពីថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ជំនួសដីកាសម្រេចទីមួយ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ការខកខានមិនបានផ្តល់ព័ត៌មានស្តីពីវិសាលភាពនៃកិច្ចស៊ើបសួរឱ្យបានទាន់ពេលវេលា ដើម្បីឱ្យជនរងគ្រោះអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន យោងតាមវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង និងការពន្យារពេលក្នុងការដាក់ឯកសារមួយចំនួនចូលទៅក្នុងសំណុំរឿង គឺជាយុត្តិកម្មពេញលេញសម្រាប់ធ្វើការពិចារណាឡើងវិញលើដីកាសម្រេចទីមួយ។

---

របស់អង្គជំនុំជម្រះសាលាដំបូង លើសំណើបន្ទាន់ស្នើឱ្យមានការពិចារណាឡើងវិញលើដីកាបង្គាប់ឱ្យអនុវត្តតាមដីកាសម្រេចទាក់ទងនឹងការរៀបចំ និងបង្ហាញករណីរបស់ក្រុមមេធាវីការពារក្តី កថាខណ្ឌ ៩-១៤។

[១៩] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារលេខ C22/I/68 កថាខណ្ឌ ២៥ និងសាលដីកាសម្រេចអំពីការពិចារណាសារជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ D364/1/6 កថាខណ្ឌ ៩ ។

[២០] រឿងក្តី Milosevic **ទល់នឹងរដ្ឋអាជ្ញា** នៅតុលាការ ICTY [ឆ្នាំ ២០០៤] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្កំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការតែងតាំងក្រុមមេធាវីការពារក្តី កថាខណ្ឌ ៩-១០ និងយោងនៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D164/4/13 កថាខណ្ឌ ២៦។

១០. **ដោយយល់ឃើញថា** មូលដ្ឋាននៅក្នុងផ្នែក ខ នឹងបង្ហាញថា ដីកាសម្រេចទីមួយមានទាំងការភ័ន្តច្រឡំ និងភាពអយុត្តិធម៌។

១១. **ដោយយល់ឃើញថា** នីតិវិធីនេះគឺស្របតាមវិធាន ២១ (១)(ក) នៃវិធានផ្ទៃក្នុង ដែលចែងថា "បទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព"។

**ខ. ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

*ក) អត្ថិភាពនៃព្យសនកម្មដោយផ្ទាល់*

១២. **ដោយយល់ឃើញថា** ដីកាសម្រេចទីមួយ បានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ ដោយផ្អែកលើមូលដ្ឋានថា គាត់មិនបានបង្ហាញថា គាត់បានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកដោយផ្ទាល់នៃការស្លាប់បងប្រុសគាត់[២១]។

១៣. **ដោយយល់ឃើញថា** ដូច្នេះ មានយុត្តិកម្មដែលត្រូវធ្វើការពិចារណាឡើងវិញលើសំអាងហេតុនេះ ដោយគិតដល់ច្បាប់ជាធរមាន និងយុត្តិសាស្ត្រ។

១៤. **ដោយយល់ឃើញថា** ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ហើយដើម្បីទទួលបានការជួសជុល ព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់នៃបទល្មើស ព្យសកម្មត្រូវតែជាព្យសកម្មផ្ទាល់ខ្លួន ដែលបានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ហើយអាចជាព្យសនកម្មខាងសម្ភារៈ ខាងរូបរាងកាយ និងខាងផ្លូវចិត្ត[២២]។

---

[២១] សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស:ច.ស ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក រ៉ូប៊ឹត ហាមីល ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D11/2/3 កថាខណ្ឌ ៥។

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣។

១៥. **ដោយយល់ឃើញថា** វិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង ចែងថា ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និងបង្ហាញជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋយ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើនដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទថា ខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព។

១៦. **ដោយយល់ឃើញទៀតថា** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តល់ "ព័ត៌មានលម្អិតអំពីឋានៈជាជនរងគ្រោះ បញ្ជាក់អំពីប្រភេទឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងភ្ជាប់មកជាមួយនូវភស្តុតាងបញ្ជាក់អំពីព្យសនកម្មដែលទទួលរង ឬការបង្ហាញអំពីពិរុទ្ធភាពរបស់ឧក្រិដ្ឋជនដែលត្រូវចោទប្រកាន់។ ពាក្យបណ្តឹងត្រូវតែមានការបញ្ជាក់ឱ្យបានត្រឹមត្រូវអំពីលំនៅដ្ឋានរបស់ជនរងគ្រោះ ការិយាល័យចុះបញ្ជីរបស់សមាគមជនរងគ្រោះដែលខ្លួនជាសមាជិក ឬអាសយដ្ឋានរបស់មេធាវី ដើម្បីងាយស្រួលដល់ការបញ្ជូន និងការជូនដំណឹង។ នៅពេលដែលអាសយដ្ឋាននេះស្ថិតនៅក្រៅប្រទេសកម្ពុជា អ្នកប្តឹងត្រូវតែផ្តល់អាសយដ្ឋានមួយនៅក្នុងប្រទេសកម្ពុជា[២៣]។

១៧. **ដោយយល់ឃើញថា** ទោះបីជា បញ្ញត្តិទាំងពីរនេះ មិនបានកំណត់លក្ខណៈពិតប្រាកដនៃទំនាក់ទំនងហេតុ និងបច្ច័យយ៉ាងណាក៏ដោយ ក៏គួរបញ្ជាក់ថា ការកំណត់លក្ខណៈនេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់នៅក្នុងដំណាក់ការស៊ើបសួរ និងការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២។

១៨. **ដោយយល់ឃើញថា** សេចក្តីណែនាំអនុវត្តដែលបានចេញ យោងតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង បានធ្វើការកត់សម្គាល់ថា "ព្យសនកម្មខាងផ្លូវចិត្តអាចរាប់បញ្ចូលការស្លាប់របស់ញាតិសន្តានដែលជាជនរងគ្រោះនៃបទឧក្រិដ្ឋបែបនោះ"។

---

[២៣] វិធាន ២៣ (ស្ទួន)(៤)នៃវិធានផ្ទៃក្នុង។

១៩. **ដោយយល់ឃើញថា** នៅក្នុងដីកាសម្រេចចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់យ៉ាងច្បាស់ថា "មានការសន្មតទុកជាមុននៃព្យសនកម្មខាងផ្លូវចិត្តសំរាប់សមាជិកសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់"[២៤]។

២០. **ដោយយល់ឃើញថា** សញ្ញាណនៃសមាជិកសាច់ញាតិជិតស្និទ្ធមិនត្រឹមតែរាប់បញ្ចូលទាំងឪពុកម្តាយ និងកូនប៉ុណ្ណោះតែ ប៉ុន្តែក៏រាប់បញ្ចូលទាំងប្តី-ប្រពន្ធ បងប្អូនប្រុស និងបងប្អូនស្រីរបស់ជនរងគ្រោះផ្ទាល់ផងដែរ[២៥]។

២១. **ដោយយល់ឃើញថា** សហចៅក្រមស៊ើបអង្កេត បានចាត់ទុកការសន្មតទុកជាមុននេះថាមិនអាចជំទាស់ ជាពិសេសក្នុងករណីដែលជនរងគ្រោះផ្ទាល់ បានស្លាប់ ឬបាត់ខ្លួនបណ្តាលមកពីអំពើមួយដែលស្ថិតក្រោមការស៊ើបសួរ"[២៦]។

---

[២៤] សំណុំរឿង 00២/១៩-0៩-២00៧/អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D404 កថាខណ្ឌ ១៤(ក)។ សូមមើលផងដែរលើរឿងក្តី Valle-Jaramillo និងអ្នកផ្សេងទៀតនៅតុលាការសិទ្ធិមនុស្សអន្តរអាមេរិកាំង (Inter-American Court of Human Rights) សាលក្រម ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២00៨ កថាខណ្ឌ ១១៩ និងរឿងក្តី Kawas-Fernandez នៅតុលាការ Inter-American Court of Human Rights សាលក្រម ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២00៩។

[២៥] អង្គការសហប្រជាជាតិ សេចក្តីសម្រេច ៤0/៣៤ ត្រូវបានអនុម័តនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ សេចក្តីប្រកាសពីគោលការណ៍មូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភបំពានអំណាច និង សេចក្តីសម្រេច ៦0/១៤៧ ត្រូវបានអនុម័តនៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២00៥ ស្តីពីគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានការដោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះដោយការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ កថាខណ្ឌ ៨។ រឿងក្តី **Thomas Lubanga Dyilo** នៅតុលាការ ICC [ឆ្នាំ ២00៨] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង I កថាខណ្ឌ ៣២។ តុលាការ Inter-American Court of Human Rights រឿងក្តី កុមារតាមចញ្ចើមថ្នល់ សាលក្រម ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២00១ កថាខណ្ឌ ៦៨។ តុលាការ Inter-American Court of Human Rights រឿងក្តី Marna Mack Chang សាលក្រម ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២00៣ កថាខណ្ឌ ២៣២ និង ២៤៤។

[២៦] សំណុំរឿង 00២/១៩-0៩-២00៧/អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានអាសយដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D404 កថាខណ្ឌ ១៤(ក)(១)។ សូមមើលផងដែរលើរឿងក្តី **Thomas Lubanga Dyilo** នៅតុលាការ ICC [ឆ្នាំ ២00៨]

២២. **ដោយយល់ឃើញថា** នៅក្នុងសាលដីកាចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១[២៧] អង្គបុរេជំនុំជម្រះ បានពិចារណាលើលក្ខណៈនៃឧក្រិដ្ឋកម្មរួមដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងទម្លាប់ជាប្រពៃណីរបស់គ្រួសារជនជាតិខ្មែរ ហើយបានលុបចោលតម្រូវការឱ្យមានទំនាក់ទំនងហេតុ និងបច្ច័យ ព្រមទាំងបានពង្រីកសញ្ញាណនៃ "ព្យសនកម្មខាងផ្លូវចិត្ត" ដោយគូសបញ្ជាក់ជាឧទាហរណ៍ដូចជា ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការឈឺចាប់ផ្លូវចិត្តដែលបុគ្គលម្នាក់បានទទួលរងដោយគ្រាន់តែរំលឹកពីហេតុការណ៍ដែលបានឃើញកាលពីជាង ៣០ ឆ្នាំមុន[២៨]។

២៣. **ដោយយល់ឃើញថា** នៅក្នុងសាលដីការបស់ខ្លួន (សេចក្តីសង្ខេបនៃសាលដីកា) ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២[២៩] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខណៈវិនិច្ឆ័យនៃចំណងពិសេសនៃក្តីស្រលាញ់ ឬការរស់នៅក្នុងបន្ទុកដែលជាប់ទាក់ទងរវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹងជនរងគ្រោះផ្ទាល់ គឺគ្របដណ្តប់ទៅលើសារៈសំខាន់នៃទំនាក់ទំនងផ្ទាល់ទៅវិញទៅមក ហើយការបំផ្លាញទំនាក់ទំនងនេះនាំឱ្យមានព្យសនកម្មដែលប៉ះពាល់ជនរងគ្រោះមិនផ្ទាល់។

---

អង្គបុរេជំនុំជម្រះ I កថាខណ្ឌ ២៣-២៥។ រឿងក្តី **Ahmad Harun និងអ្នកផ្សេងទៀត**នៅតុលាការ ICC [ឆ្នាំ ២០០៥] អង្គបុរេជំនុំជម្រះ I កថាខណ្ឌ ៣៥។ តុលាការសិទ្ធិមនុស្សអឺរ៉ុប European Court of Human Rights (ECHR) [ឆ្នាំ ២០០៨] រឿងក្តី Kurt (15/1997/799/1002) សាលក្រម អង្គជំនុំជម្រះ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៣០-១៣៤។តុលាការ ECHR រឿងក្តី Cakici (23657/94) ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៩។ តុលាការ ECHR រឿងក្តី Bamaca Velasquez សាលក្រម អង្គជំនុំជម្រះ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ១៤៧។តុលាការ ECHR រឿងក្តី Blake សាលក្រម អង្គជំនុំជម្រះ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១១៤-១១៦។ តុលាការ IACHR រឿងក្តី La Cantuta អង្គសេចក្តី សំណង និងសោហ៊ុយ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១២៣។ តុលាការ IACHR រឿងក្តី Myrna Mack Chang មតិយោបល់ស្របដែលមានសំអាងហេតុរបស់ ចៅក្រម Sergio Garcia-Ramirez កថាខណ្ឌ ៥៦, ៥៧ និង ៥៩-៦២។

[២៧] សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៧៦ អ.ប.ជ១១២ អ.ប.ជ១១៣ អ.ប.ជ១១៤ អ.ប.ជ១១៥ អ.ប.ជ១៤២ អ.ប.ជ១៥៧ អ.ប.ជ១៦៤ អ.ប.ជ១៦៥ អ.ប.ជ១៧២) សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ២៣-២៨។

[២៨] ដូចចុងទំព័រខាងលើ កថាខណ្ឌ ២៤ ។

[២៩] សំណុំរឿង ០០១/១៨-០៧-២០០៧/អ.វ.ត.ក/អ.ត.ក (កាំង ហ្គេកអ៊ាវ) សេចក្តីសង្ខេបនៃសាលដីកា ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ F26/3។

២៤. **ដោយយល់ឃើញថា** ដូច្នេះ លក្ខណៈវិនិច្ឆ័យនេះអនុវត្តចំពោះបុគ្គលទាំងអស់ដែលអះអាងថាជាជនរងគ្រោះមិនផ្ទាល់ ទោះបីថា ពួកគេគឺជា ឬក៏មិនមែនជាសមាជិកគ្រួសារក្តី ហើយក៏អនុវត្តផងចំពោះសញ្ញាណនៃព្យសនកម្មស្ថិតនៅក្នុងអត្ថន័យនៃមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានចំពោះជនរងគ្រោះមិនផ្ទាល់។

២៥. **ដោយយល់ឃើញទៀតថា** ការបាត់ខ្លួនដោយបង្ខំ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងចុងក្រោយបំផុតអំពើឃាតកម្មទៅលើសមាជិកគ្រួសារណាម្នាក់ អាចបង្កឲ្យមានទម្រង់ផ្សេងទៀតនៃការឈឺចាប់ ទុក្ខព្រួយ និងព្យសនកម្មដែលមានលក្ខណៈផ្សេង ដូចជា ការបាត់បង់ផ្នែកហិរញ្ញវត្ថុ ដល់សមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះ។

២៦. **ដោយយល់ឃើញថា** ដូច្នេះ មានយុត្តិកម្ម និងសំអាងហេតុសមស្របដែលត្រូវជួយសមាជិកគ្រួសារផ្ទាល់កាត់បន្ថយបន្ទុកនៃផលវិបាកព្យសនកម្ម។

២៧. **ដោយយល់ឃើញថា** ដោយគិតដល់មូលដ្ឋានតែមួយគត់ដែលបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ ដូចដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតនោះ ដីកាសម្រេចទីមួយស្តែងឲ្យឃើញថាមិនមានមូលដ្ឋានឡើយ ពីព្រោះថា សញ្ញាណនៃព្យសនកម្មខាងផ្លូវចិត្ត ត្រូវបានកំណត់មិនបានត្រឹមត្រូវតាមច្បាប់ ដោយមិនបានពិនិត្យទៅលើយុត្តិសាស្ត្រដែលបានលើកឡើង។

២៨. **ដោយយល់ឃើញទៀតថា** ដីកាសម្រេចនេះអយុត្តិធម៌ទាំងស្រុង ដោយក្នុងនោះ ដីកាសម្រេចនេះបានធ្វើឲ្យអ្នកដាក់ពាក្យសុំ បាត់បង់លទ្ធភាពចូលរួមក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនដែលត្រូវចោទថាទទួលខុសត្រូវចំពោះការបាត់ខ្លួនបងប្រុសរបស់គាត់ និងលទ្ធភាពទាមទារសំណង តាមលទ្ធភាពសមស្រប យោងតាមវិធាន ២៣(១)(ក) និង(ខ) នៃវិធានផ្ទៃក្នុង។

*ខ) ការវិភាគតម្រូវការផ្សេងទៀតសម្រាប់ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ*

២៩. **ដោយយល់ឃើញថា** ដូច្នេះ ការកំណត់ថាតើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំ បានបំពេញ ឬមិនបានបំពេញតាមតម្រូវការផ្សេងទៀតសម្រាប់ភាពអាចទទួលយកបាន យោងតាមវិធាន ២៣ ស្ទួន នៃវិធានផ្ទៃក្នុង គឺជាការសមស្រប។

៣០. **ដោយយល់ឃើញថា** គួរឱ្យកត់សម្គាល់ដែរថា អ្នកដាក់ពាក្យសុំបានផ្តល់ព័ត៌មានដែលត្រូវការទាំងអស់នៅក្នុងទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ[៣០]

៣១. **ដោយយល់ឃើញថា** នៅក្នុងឯកសារឧបសម្ពន្ធមួយ[៣១] អ្នកដាក់ពាក្យសុំបានព្យាយាមពិពណ៌នាយ៉ាងលម្អិតអំពីអំពើដែលជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ អាចត្រូវចោទប្រកាន់ ជាអំពើដែលនាំឱ្យមានការចាប់ខ្លួនបងប្រុសរបស់គាត់ឈ្មោះ ឃែរី ចច ហាមីល (Kerry George Hamill) នៅពេលដែលគាត់បានធ្វើដំណើរតាមទូកក្តោងឈ្មោះ Foxy Lady តាមបណ្តោយឆ្នេរកោះតាង កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៨ ហើយធ្វើឱ្យគាត់បាត់ខ្លួន និងទំនងជាត្រូវគេសម្លាប់ ដោយយោងតាមចម្លើយរបស់ ចន ឌូហ៊ើស (John Dewhirst) ដែលមានវត្តមាននៅលើទូកនោះដែរ ហើយក្រោយមកត្រូវបានដាក់ឃុំឃាំងជាមួយបងប្រុសរបស់គាត់នៅមន្ទីរ ស២១។

៣២. **ដោយយល់ឃើញថា** គាត់ក៏បានពិពណ៌នាយ៉ាងត្រឹមត្រូវអំពីលក្ខណៈនៃព្យសនកម្មរបស់គាត់ យោងតាមចម្លើយសាក្សីរបស់គាត់ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ នៅក្នុង សំណុំរឿង ០០១។

៣៣. **ដោយយល់ឃើញថា** ដូច្នេះ អ្នកដាក់ពាក្យសុំ ពិតជាបានបំពេញតាមតម្រូវការសម្រាប់ការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣។

---

[៣០] ផ្នែកគាំពារជនរងគ្រោះ ទម្រង់បែបបទស្តីពីជនរងគ្រោះ លេខ 11-VSS-0002 ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១១ សំណុំរឿង ០០៣/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស ឯកសារ D11/2។

[៣១] ដូចចុងទំព័រខាងលើ លេខ ERN 00៦៨១១១២-00៦៨១១២០។

៣៤. **ដោយយល់ឃើញថា** គាត់ត្រូវបានទទួលស្គាល់រួចហើយជាដើមបណ្តឹងរដ្ឋប្បវេណី ទាំងនៅក្នុងរឿង ០០១ នៅឆ្នាំ ២០០៩ នៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារមួយជីវិត កាលពីថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ និង នៅក្នុងសំណុំរឿង ០០២ នៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ ដែលបច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះ។

៣៥. ចុងក្រោយបំផុត**ដោយយល់ឃើញថា** តាមលក្ខណៈផ្លូវច្បាប់ គេអាចមានការងឿងឆ្ងល់លើកាលៈទេសៈគួរឱ្យភ្ញាក់ផ្អើល ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រ៉ូបឺត ហាមីល ត្រូវបានបដិសេធលើកដំបូង។

## អាស្រ័យហេតុនេះ សម្រេច

៣៦. **ប្រកាស**ទទួលយកសំណើរបស់ រ៉ូបឺត ហាមីល ដែលស្នើសុំឱ្យមានការពិចារណាឡើងវិញលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់។

៣៧. **យល់ព្រមតាម**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រ៉ូបឺត ហាមីល ហើយ អនុញ្ញាតឱ្យគាត់មានលទ្ធភាពចូលពិនិត្យមើលឯកសារសំណុំរឿង ០០៣។

៣៨. **ប្រកាស**ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នៅក្នុងសំណុំរឿង ០០៤ នឹងត្រូវយកមកពិចារណាដាច់ដោយឡែក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង**

**International Reserve Co-Investigating Judge**

**Laurent Kasper-Ansermet**